# ឧបករណ៍តន្ត្រី “ព្ញយ”

“**ព្ញយ**” ជាឧបករណ៍តន្ត្រីគ្រឿងផ្លុំមួយដែលមានប្រើនៅក្នុងចំណោមជនជាតិដើមភាគតិចរស់នៅតាមតំបន់ខ្ពង់រាបនិងតំបន់ភ្នំនៃប្រទេសកម្ពុជាមានដូចជា ព័រ កួយ ស្ទួយ និងព្នង ជាដើម។

“**ព្ញយ**” មានបំពង់សូរធ្វើពីឫស្សីពកចំនួនពីរ បី ឬប្រាំ រហូតដល់ប្រាំពីរ ស៊កចូលទៅក្នុងប្រអប់សូរ ធ្លាយពីម្ខាងទៅម្ខាងដោយចងផ្ដុំគ្នាជាមួយជុំដោយចម្រៀកផ្ដៅ។ បំពង់សូរនីមួយៗ មានចោះរន្ធមួយនិងអណ្ដាតមួយ ហើយមានប្រវែងមិនស្មើគ្នាឡើយ គឺបំពង់សូរខ្លី មានសំឡេងខ្ពស់ ឯបំពង់សូរវែង មានសំឡេងទាប។ ប្រអប់សូររបស់ព្ញយ ធ្វើពីផ្លែឃ្លោកទុំមូលស្ងួតនិងមានត្រដង់បំពង់ខ្យល់មួយតូចវែងសម្រាប់ផ្លុំឱ្យឮសូរ កាលណាអ្នកលេងដាក់ម្រាមដៃខ្ទប់រន្ធហើយផ្លុំចូលឬដកដង្ហើមចេញ តាមបំពង់ឃ្លោកខ្យល់នៃឧបករណ៍។

យើងឃើញមានឧបករណ៍ព្ញយ ប្រើជាមួយនឹងស្គរនិងអ្នកច្រៀងនៅពេលសែនព្រេន បន់អ្នកតានិងឡើងអ្នកតា ដើម្បីសុំសេចក្ដីសុខសួស្ដីសិរីមង្គលឲ្យរួចផុតពីគ្រោះចង្រៃនិងមហន្តរាយផ្សេងៗ។ យើងក៏ឃើញមានឧបករណ៍ព្ញយ សម្ដែងនៅក្នុងវង់តន្ត្រីលេងកំដររបាំទន្សោងក្នុងចំណោមជនជាតិដើមភាគតិច ព័រ ខេត្តពោធិសាត់និងរបាំព្ញយស្ទួយក្នុងចំណោមជនជាតិដើមភាគតិច ស្ទួយ ខេត្តកំពង់ស្ពឺ។

សព្វថ្ងៃនៅកម្ពុជា ឧបករណ៍ព្ញយ ស្ទើរតែបាត់បង់ ដោយយើងមិនបានចាប់អារម្មណ៍គាំទ្រនិងលើកទឹកចិត្តដល់អ្នកបដិបត្តិនិងថែរប្បធម៌ដ៏កម្រនេះ ហើយយុវជនយុវនារីបច្ចុប្បន្ន ក៏មិនបានសិក្សារៀនសូត្រដើម្បីយល់ដឹង ថែរក្សា និងបន្តប្រពៃណីនេះទៅមុខទៀតដែរ។ តាមរយៈការស្រាវជ្រាវរបស់យើងនៅឆ្នាំ២០២០ ក្នុងសហគមន៍ស្ទួយត្រាង ឃុំសង្កែសាទប ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ គឺនៅមានតែចាស់ៗពីរបីនាក់តែប៉ុណ្ណោះដែលនៅចេះធ្វើ និងសម្ដែងឧបករណ៍ព្ញយ។ ឯក្មេងៗស្ទួយ ជំនាន់ឥឡូវនេះ មិនបានយកចិត្តទុកដាក់ រៀនសូត្រធ្វើនិងសម្ដែងព្ញយទៀតឡើយ ដែលជាការព្រួយបារម្មណ៍មួយចំពោះអនាគតនៃឧបករណ៍នេះទៅថ្ងៃមុខៗ។ ម្យ៉ាងវិញទៀត ក្នុងបច្ចុប្បន្នកាល ឧបករណ៍

អត្ថបទដោយ៖ បណ្ឌិត សំ សំអាង

*ព្វយ ក៏មានការវិវត្តក្នុងការធ្វើ មានដូចជាការជំនួសផ្លែឃ្លោកដោយត្រឡោកដូង ព្រោះពិបាករកផ្លែឃ្លោក ដោយ**សារ**គេមិនសូវដាំឃ្លោកប្រភេទនេះទៀតឡើយ។*[១]







[១] ឃុំសង្កែសាទប ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ មានប្រជាជនរស់នៅចំនួន ២៣៩គ្រួសារ ឬ ៩៨៤នាក់ (ស្រី ៥៣៥នាក់) (ឆ្នាំ២០២០)។

អត្ថបទដោយ៖ បណ្ឌិត សំ សំអាង






## ឯកសារយោង


កែវ ណារុំ. (២០១១). *តន្ត្រីនៅប្រទេសខ្មែរ*. ភ្នំពេញ: គ្រឹស្ថានបោះពុម្ពផ្សាយនគរវត្ត។

ជួន ណាត. (១៩៦៧). *វចនានុក្រមខ្មែរ*. ភ្នំពេញ: ពុទ្ធសាសនបណ្ឌិត្យ។

ពេជ្រ សល់. (១៩៧០). *អំពីលំនាំសង្ខេបនៃភ្លេងខ្មែរ*. ភ្នំពេញ: ពុទ្ធសាសនបណ្ឌិត្យ។

*Musique Khmère*. (1969). Phnom Penh: Imprimerie Sangkum Réastr Niyum.

Sam, Sam-Ang. (2002). *Musical Instruments of Cambodia*. Osaka: National Museum of Ethnology.


អត្ថបទដោយ៖ បណ្ឌិត សំ សំអាង

ENGLISH ABSTRACT

*Ploy* is a free-reed mouth organ. The number of pipes, made of bamboo, varies from two, three, or five to seven. Each of the pipes has one finger-hole and a reed. It sounds when a player covers the finger-hole, inhaling or exhaling through the opening of the gourd—its resonator box.

*Ploy* is found among several indigenous ethnic groups, living on the plain and in the mountainous areas in Cambodia, including the Poar, Kuoy, Suoy, and Pnorng. It is used in a small ensemble along with a drum and singers in ethnic guardian spirit worship ceremonies to ward off evils and for community blessing. *Ploy* is also used in the music ensemble to accompany folk dances, namely, Wild Ox Dance of the indigenous ethnic group Poar in Pursat province, and Ploy Suoy Dance of the Suoy in Kampong Spoeu province.

In 2020, our research team conducted studies on the Suoy Trang indigenous ethnic group and community in Sangkae Satorb commune (with 239 families or 984 persons, 535 are females), Orall district, Kampong Spoeu province where the Suoy under study still make and play the mouth organ—*ploy* in limited ceremonies when they call for the *ploy* ensemble. The Suoy still somehow maintain and celebrate a handful of Suoy ethnic ceremonies, evolving around their lives and agrarian cycles.

Nowadays in Cambodia, the *ploy* is on the verge of disappearing as little attention is paid to such a tradition, whereas the young do not learn in order to preserve and continue it. In the Suoy Trang community, Sangkae Satorb commune, there remain only a couple of elderly ethnic members who know how to make the *ploy* and play it. Besides, there have been changes in the *ploy*-making whereby the dried gourd is replaced by dried coconut-shell as the ethnic group no longer plants the gourds, while the coconut-shells are more readily accessible and easier to find.

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION

អត្ថបទដោយ៖ បណ្ឌិត សំ សំអាង